**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ : ១៣១៤ រ.ដ.ប

ថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**<u>កម្មវត្ថុ</u>** : ស្តីពីការផ្សព្វផ្សាយអាហារូបករណ៍របស់រដ្ឋបាលខេត្តជាំងស៊ូ (Jiangsu) នៃសាធារណរដ្ឋប្រជាមានិតចិនសម្រាប់ឆ្នាំ២០១៨។

**<u>យោង</u>** : លិខិតលេខ ១៦ អយក.ស.ជ.ណ ចុះថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** ថា រដ្ឋបាលខេត្តជាំងស៊ូ (Jiangsu) នៃសាធារណរដ្ឋប្រជាមានិតចិនក្រោមកម្មវិធីអាហារូបករណ៍ "The 2018 Jasmine Jiangsu Tertiary Education Scholarship for Southeast Asia (JJTES-SEA)" នឹងផ្តល់អាហារូបករណ៍ចំនួន៨៧កន្លែង ដល់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍រួមទាំងប្រទេសកម្ពុជាផងដែរ ដើម្បីទៅបន្តការសិក្សាថ្នាក់ឧត្តមសិក្សា (Undergraduate) និងថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈកម្រិត៣ (Vocational Tertiary Level) នៅតាមគ្រឹះស្ថានឧត្តមសិក្សានានានៃខេត្តជាំងស៊ូ (Jiangsu) សម្រាប់ឆ្នាំ២០១៨។ អាហារូបករណ៍ខាងលើនេះចែកចេញជាពីរផ្នែកគឺ អាហារូបករណ៍១០០% (Full scholarships) ចំនួន៤៤កន្លែង និងអាហារូបករណ៍មិនពេញលេញ (Partial scholarships) ចំនួន៤៣កន្លែង។

ចំពោះការដាក់ពាក្យសុំ និងព័ត៌មានលម្អិតផ្សេងៗអំពីអាហារូបករណ៍ខាងលើសូមចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន http://www.bit.ly/jasminejiangsu2018។ សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទំនាក់ទំនងដោយផ្ទាល់តាមរយៈសារអេឡិចត្រូនិក jasminescholarship2018.seameo@gmail.com។

ចំពោះកាលបរិច្ឆេទឈប់ទទួលពាក្យត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

ប្រាក់ សំរឿង

**<u>សូមទំនាក់ទំនង៖</u>**

- លោក ងួន គីមសេង
- ទូរស័ព្ទលេខ: ០១១ ៣២២ ២២៧